00224505

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**សំណុំរឿងលេខ:** ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ.០២)

**ដាក់តម្កល់ជូន:** អង្គបុរេជំនុំជម្រះ

**កាលបរិច្ឆេទដាក់ឯកសារ:** ១៨ កញ្ញា ២០០៨

**ភាគីអ្នកតម្កល់:** មេធាវីរបស់លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច

**ភាសាដើម:** ភាសាបារាំង

**ប្រភេទឯកសារ:** សាធារណៈ

---

## ចម្លើយចំពោះសំណើដែលដាក់ដោយលោក អៀង សារី
## នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨

---

<u>បញ្ជូនដោយ:</u>

**មេធាវីរបស់ជនត្រូវចោទ លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច**

លោក ការ សាវុត្ថ

លោក François ROUX

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 18 / 09 / 2008
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 18 / 9 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Kauv Keo Ratanak

<u>បញ្ជូនទៅ:</u>

**ចៅក្រមអង្គបុរេជំនុំជម្រះ**

លោកចៅក្រម ប្រាក់ គឹមសាន ប្រធាន

លោកចៅក្រម Rowan DOWNING

លោកចៅក្រម ន័យ ថុល

លោកស្រីចៅក្រម Katinka LAHUIS

លោកចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោក គង់ ពិសី

លោក ហុង គឹមសួន

លោក យ៉ុង ផានិត

លោក Silke STUDZINSKY

លោក គីម ម៉េងឃី

លោក Martine JACQUIN

## ជូនចំពោះអង្គបុរេជំនុំជម្រះ

1. ក្រុមមេធាវីការពារក្តីកត់សម្គាល់ថា លោក **អៀង សារី** ត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស។

2. ក៏ប៉ុន្តែ តាមសេចក្តីសម្រេចចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧[1] សហចៅក្រមស៊ើបអង្កេតបានបង្គាប់ឱ្យបំបែកសំណុំរឿងជាពីរ គឺសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស និង សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ហើយការបំបែកសំណុំរឿងនេះ គឺ *"ដើម្បីជាប្រយោជន៍ដល់យុត្តិធម៌"*។

3. ដោយឡែក ក្រុមមេធាវីការពារក្តីកត់សម្គាល់ថា នៅក្នុងដីកាបំបែកសំណុំរឿងនេះដែលមិនមានការជំទាស់ ហើយដោយហេតុដូច្នេះបានក្លាយទៅជាស្ថាពរនោះ មានចែងថា៖ *"យើងត្រូវមានសេចក្តីសម្រេចមួយឱ្យបានលឿនចំពោះករណី ឌុច ដោយហេតុថា ជននេះត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅក្នុងក្របខណ្ឌនីតិវិធីផ្សេងអស់រយៈពេល៨ឆ្នាំមកហើយ (...)"*។

4. ក្រុមមេធាវីការពារក្តីយល់ឃើញថា ការបញ្ជូនសំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស ទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឱ្យបានឆាប់បំផុត គឺជាការសំខាន់ ដើម្បីឱ្យ **ឌុច** អាចទទួលបាននូវការជំនុំជម្រះក្តីឱ្យបានឆាប់ នៅក្នុងក្របខណ្ឌនៃការជំនុំជម្រះជាសាធារណៈមួយ ហើយនេះគឺដើម្បីជាប្រយោជន៍របស់ **ឌុច** ខ្លួនឯងផង និងរបស់ជនរងគ្រោះផង។[2]

5. ក្រុមការពារក្តីកត់សម្គាល់ថា បើតាមសំណើដែលដាក់នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ ដោយលោក **អៀង សារី** នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ក្នុងសំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សាម៉ីខ្លួននិងភាគីដទៃទៀតនៅក្នុងសំណុំរឿងនេះ ត្រូវបានអញ្ជើញដោយដីការបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ ឱ្យបង្ហាញនូវគ្រប់ការកត់សម្គាល់នានា

---

[1] សូមអាន *"ដីកាបំបែកសំណុំរឿង"* ដែលចេញដោយសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ (D18)។

[2] សូមអាន *"ចម្លើយរបស់ក្រុមការពារក្តីចំពោះបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨"* ដែលដាក់តម្កល់ជូនអង្គបុរេជំនុំជម្រះ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ (D99/3/8)។

ដែលទាក់ទងនឹងការអនុវត្តន៍ជាយថាហេតុនៃសញ្ញាណសហឧក្រិដ្ឋកម្មរួម ដើម្បីអាចមានការជជែកគ្នាដោយជំទាស់ទៅលើបញ្ហានេះ ជាមួយនឹងសហព្រះរាជអាជ្ញានិងភាគីដទៃទៀតនៅក្នុងសំណុំរឿង[3]។

6. ដោយហេតុដូច្នេះ ក្រុមការពារក្តីសូមស្នើឱ្យគេបញ្ជូនលោក **អៀង សារី** ទៅបង្ហាញនូវការកត់សម្គាល់របស់គាត់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត នៅក្នុងក្របខណ្ឌនៃសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស។

**តាមរយៈហេតុផលទាំងនេះ**

7. ក្រុមការពារក្តីសូមស្នើដោយគោរពទៅអង្គបុរេជំនុំជម្រះ មេត្តា៖

ដោយបានឃើញដីការបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨

- **បញ្ជូន** លោក **អៀង សារី** ទៅបង្ហាញនូវសេចក្តីកត់សម្គាល់របស់គាត់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត នៅក្នុងក្របខណ្ឌនៃសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស។

- **បដិសេធ** សំណើដែលដាក់ដោយលោក អៀង សារី នៅក្នុងក្របខណ្ឌនៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស។

- **បញ្ជូន** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស ទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីឱ្យ **ឌុច** អាចទទួលបានការជំនុំជម្រះក្តីដោយឆាប់រហ័ស។

---

[3] សូមអាន *"ដីកាស្តីពីការអនុវត្តទម្រង់នៃភាពទទួលខុសត្រូវដែលត្រូវបានគេស្គាល់ក្រោមឈ្មោះថា សញ្ញាណសហឧក្រិដ្ឋកម្មរួម"* ដែលចេញដោយសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ (D97/III)។

# សូមរក្សាសិទ្ធិគ្រប់យ៉ាង

| | | | |
|---|---|---|---|
| ១៨-៩-២០០៨ | សម្រាប់មេធាវីទាំងពីររូប<br>មេធាវីម្នាក់ក្នុងចំណោមមេធាវី<br>ទាំងពីររូប<br><br>លោក **ការ សាវុត្ថ** | ភ្នំពេញ | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |